# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាសម្រាប់វិញ្ញាណក្ខន្ធលោកអភិបាល អ៊ីវ រ៉ាមូស
# តាំងគោក ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១
## ខ្ញុំនេតើ! ជាអ្នកបម្រើរបស់ព្រះអង្គ

**អត្ថបទទី១៖ កំណើតពិភពលោក ២២,១-២.៩-១៣.១៥-១៨**

យើងដឹងថាអ្នកពិតជាកោតខ្លាចព្រះជាម្ចាស់មែន។ កណ ២២,១២

**អត្ថបទទី២៖ រ៉ូម ៨,៣១ខ-៣៤**

តើនរណាអាចចោទប្រកាន់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស បើព្រះអង្គប្រោសគេឲ្យបានសុចរិតហើយនោះ? រម ៨,៣៣

**ដំណឹងល្អ៖ ម៉ាកុស ៩,២-១០**

«តើ"រស់ឡើងវិញ" មានន័យដូចម្ដេច?»។មក ៩,១០

លោកអភិបាល អ៊ីវ ជាទីគោរពស្រឡាញ់!

លោកអភិបាល បានប្រារព្ធខួបកំណើត៩៣ឆ្នាំ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ និងខួប៥៨ឆ្នាំ ជាអភិបាលនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១។ នៅក្នុងភាពសម្ងាត់ក្នុងមន្ទីរពេទ្យ នៅពេលនោះ រូបកាយរបស់លោកអភិបាល បីដូចជាសម្រាន្តលក់ដោយសារកូវីដ-១៩។ កូវីដ-១៩ដែលបានសម្លាប់មនុស្សទូទាំងពិភពលោកក្នុងមួយឆ្នាំ ជាង២លាន៤០ម៉ឺននាក់។ ប្រសិនបើយើងគិតមើល ២លាន៤០ម៉ឺននាក់ដែលបានស្លាប់ដោយសារជំងឺកូវីដ-១៩ គឺស្មើនឹងចំនួនបងប្អូនខ្មែរដែលបានស្លាប់នៅក្នុងសម័យខ្មែរក្រហមដែរ។

នៅព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ ម៉ោង១និង៣០នាទីរម្លងអធ្រាត្រនៅប្រទេសបារាំង លោកអភិបាលជាទីស្រឡាញ់របស់យើងខ្ញុំ បានភ្ញាក់ឡើងនៅក្បែរព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូដែលលោកអភិបាលបានបម្រើ ព្រះយេស៊ូដែលលោកអភិបាលបានស្រឡាញ់អស់ពីដួងចិត្តអស់រយៈពេល៦៨ឆ្នាំជាបូជាចារ្យ និង៥៨ឆ្នាំជាលោកអភិបាល។ ពិតមែនមេរោគកូវីដ-១៩ដ៏តូចនេះបានឈ្នះលោកអភិបាលយើង នៅពេលយើងមើលឃើញលោកអភិបាល ដែលបានរស់នៅក្នុងកាលៈទេសៈយ៉ាងពិបាក ដែលបានឃើញមនុស្សយ៉ាងច្រើនស្លាប់ ដែលបានឃើញមនុស្សជាច្រើនមានជីវិតឡើងវិញ យើងគិតថាជីវិតរបស់លោកអភិបាលនៅលើផែនដីនេះ ទៅជាជីវិតអស់កល្បជានិច្ចដែលមិនអាចស្លាប់បានទេ។ ប៉ុន្មានដងប៉ុន្មានសារ ដែលលោកអភិបាលបានស្ដាប់អត្ថបទគម្ពីរដែលយើងលឺថ្ងៃនេះ គឺព្រះយេស៊ូដែលបានឡើងលើភ្នំ គឺព្រះយេស៊ូដែលបានណែនាំឱ្យក្រុមសាវ័កពោរពេញដោយសេចក្តីសុខ នៅពេលព្រះអង្គបង្ហាញខ្លួនជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ប៉ុន្មានដងប៉ុន្មានសារ លោកអភិបាលបានឡើងលើភ្នំដែរ និងប៉ុន្មានដងប៉ុន្មានសារលោកអភិបាលបានចុះពីភ្នំ ចូលនៅក្នុងភាពដ៏ពិបាក ការបណ្តេញចេញ

សម្លាប់ សង្ស័យ...។ ខ្ញុំជឿថា ប៉ុន្មានដងលោកអភិបាល បានសួរខ្លួនឯងដែរ "**តើព្រះជន្មរស់ឡើងវិញមានន័យដូចម្ដេច?**" ដូចក្រុមសាវ័កពីដើម។

បងប្អូនជាទីស្រឡាញ់!

ព្រឹកនេះនៅតាំងគោក នៅក្បែរឈើឆ្កាងនៃមរណសាក្សី ជាឈើឆ្កាងដែលលោកអភិបាល អ៊ីវ បានគិតរចនានិងគូរផ្ទាល់ដៃ ដើម្បីប្រារព្ធថ្ងៃនៃមរណសាក្សីដែលសម្ដេចប៉ាប យ៉ូហាន ប៉ូល ទី២ បានបង្កើតនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០០។ ជាកន្លែងដែលលោកអភិបាលបានមកថ្វាយអភិបូជាលើទឹកដីប្រទេសកម្ពុជាចុងក្រោយ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៤ នៅលើគ្រែរបស់លោកអភិបាល ឆ្នារ សាឡាស។ នៅពេលនេះ យើងជាគ្រីស្តបរិស័ទ ជាបូជាចារ្យ ជាបងប្រុសបងស្រី ជាបងប្អូនដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងរួមគ្នានឹករលឹកដល់គ្រូគង្វាលដ៏សប្បុរស ដែលអស់មួយជីវិតបានធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ ដើម្បីបម្រើព្រះសហគមន៍លើទឹកដីប្រទេសកម្ពុជា។ នៅពេលនេះ ដូចកូនចៅនិយាយទៅលោកតា ដោយសារប្រវត្តិសាស្ត្ររបស់លោកអភិបាល អ៊ីវ ភ្ជាប់នឹងប្រវត្តិសាស្ត្រដ៏អស្ចារ្យនៃពិភពលោក នៃព្រះសហគមន៍។ ភ្ជាប់នឹងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា និងព្រះសហគមន៍នៅប្រទេសកម្ពុជាដែលយើងស្គាល់សព្វថ្ងៃ។ បងប្អូនយ៉ាងច្រើន ដែលកំពុងស្ដាប់ជាយុវជនយុវនារី ជាគ្រីស្តបរិស័ទថ្មីៗ ជាសាសនទូតថ្មីៗ មិនដែលស្គាល់លោកអភិបាល អ៊ីវ។ ក៏ប៉ុន្តែ ព្រះសហគមន៍ដែលយើងស្គាល់សព្វថ្ងៃ ព្រះសហគមន៍ដែលជាគ្រួសាររបស់យើងនៅលើទឹកដីប្រទេសកម្ពុជាសព្វថ្ងៃ គឺជាផ្លែដ៏អស្ចារ្យដែលលោក អ៊ីវ បានប្រគល់ឱ្យយើងដោយជីវិតរបស់គាត់។

លោក អ៊ីវ ជាទីស្រឡាញ់!

នៅពេលខ្ញុំអាននិងនឹករលឹកដល់ជីវិតរបស់លោកអភិបាល បីដូចជាខ្ញុំនឹកឃើញដល់មុខរបស់លោកដែលគ្រប់ពេលវេលាបានញញឹម បានសើច ជាពិសេសបានលើកទឹកចិត្តខ្ញុំដែលជាបូជាចារ្យថ្មីក៏ដូចជាអភិបាលថ្មី។ នៅពេលយើងបានស្ដាប់អំពីដំណឹងនៃមរណភាពរបស់លោកតា ពេលហ្នឹងប្រទេសកម្ពុជាជាពេលវេលាព្រះចន្ទពេញបូណ៌មី ដែលកំពុងរះឡើងសភ្លឺដូចព្រះយេស៊ូនៅលើភ្នំថ្ងៃនេះ។ នៅពេលខ្ញុំនឹកឃើញព្រះចន្ទពេញបូណ៌មី នៅពេលខ្ញុំទទួលដំណឹងអំពីមរណភាពរបស់លោក អ៊ីវ ណែនាំឱ្យខ្ញុំនឹកឃើញដល់ប្រាសាទបាយន្ត ខ្ញុំនឹកឃើញដល់ព្រហ្មវិហារធម៌ទាំងបួន គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ខ្ញុំគិតថាពិតមែននេះជាជីវិតរបស់លោកតា។ ខ្ញុំនឹករលឹកដល់ថ្ងៃដែលខ្ញុំមានមោទនភាព និងទទួលបានអំណរសប្បាយយ៉ាងច្រើន នៅពេលខ្ញុំបានឃើញលោកតាបាននៅដល់វិសាលវិហារសន្តសិលានៅទីក្រុងរ៉ូម នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២។ នៅពេលនោះ ខ្ញុំបានចូលរួមមហាសន្និបាតលោកអភិបាលទូទាំងពិភពលោក ដើម្បីគិតអំពីរបៀបប្រកាសដំណឹងល្អសាជាថ្មី។ នៅពេលហ្នឹង សម្ដេចប៉ាប បេណេទិគ្ទ ទី១៦ បានអញ្ជើញលោកអភិបាលមួយចំនួន នៅពេលនោះនៅសល់តែ១២អង្គដែលបានចូលរួមនៅក្នុងមហាសន្និបាតវ៉ាទីកង់ទី២ ដើម្បីប្រារព្ធខួប៥០ឆ្នាំនៃមហាសន្និបាតហ្នឹង។ នៅពេលខ្ញុំដើរជាមួយលោកអភិបាល អ៊ីវ ខ្ញុំគិតថាខ្ញុំមានសំណាងណាស់ដោយបានស្គាល់លោកអភិបាលដូចនេះ។

លោកមានអាយុទើបតែ៣៥ឆ្នាំ ព្រះជាម្ចាស់បានជ្រើសរើសឱ្យធ្វើជាអភិបាលសម្រាប់ព្រះសហគមន៍កាតូលិកកម្ពុជា។ នេះជាអំណោយទានយ៉ាងពិសេស សម្រាប់ព្រះសហគមន៍យើងនៅប្រទេសកម្ពុជា ដែលលោកអភិបាលបានចូលរួមនៅក្នុងមហាសន្និបាតវ៉ាទីកង់ទី២ ទាំង៣ដង។ នៅក្នុងពេលវេលាមួយដ៏អស្ចារ្យ សម្រាប់ប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍នៅលើផែនដី នៅពេលលោកអភិបាលត្រលប់មកវិញ លោកអភិបាលនៅក្មេងពោរពេញដោយកម្លាំង ពោរពេញដោយគំនិតថ្មី ដើម្បីយកចិត្តទុកដាក់អនុវត្តមហាសន្និបាតទី២លើទឹកដីកម្ពុជា។ ពិតមែន ភាសាខ្មែរបានទៅជាអាទិភាពក្នុងពិធីបុណ្យ នៅក្នុងការអប់រំជំនឿ នៅក្នុងការអានគម្ពីរ ការសន្ទនារវាងសាសនានិងសាសនា ជាពិសេសជាមួយពុទ្ធសាសនាទៅជាសេចក្តីពិត។ ណែនាំឱ្យវប្បធម៌ខ្មែរចូលយ៉ាងជ្រៅនៅក្នុងព្រះសហគមន៍ ដែលគេមើលឃើញថាជាព្រះសហគមន៍បរទេសបានណែនាំឱ្យគេស្គាល់បន្តិចម្តងៗ ដោយសារការដឹកនាំរបស់លោកអភិបាលទៅជាការពិត។ នៅពេលហ្នឹង ជាពេលវេលាដើម្បីបង្កើតក្រុមលោកអភិបាល អរគុណដល់លោកអភិបាល អ៊ីវ ដែលមានគំនិតយ៉ាងពិសេស ដោយបានណែនាំឱ្យព្រះសហគមន៍កម្ពុជានិងព្រះសហគមន៍ឡាវ ទៅជាក្រុមលោកអភិបាលតែមួយ (CELAC)។ ជាពេលវេលា ដែលលោកអភិបាលបានសំណូមពរទៅទីក្រុងរ៉ូម ឱ្យបែងចែកព្រះសហគមន៍កម្ពុជាជាបីភូមិភាគ មានភូមិភាគភ្នំពេញ ភូមិភាគកំពង់ចាម និងភូមិភាគបាត់ដំបង ដើម្បីឱ្យមានគ្រូគង្វាលតាមកន្លែងនីមួយៗ និងភ្ជាប់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គ។ ជាពេលវេលាដែលលោកអភិបាល បានយកចិត្តទុកដាក់ដើម្បីអប់រំយុវជន និងបង្កើតមហាទេវវិទ្យាល័យនៅជ្រោយចង្វារ ដើម្បីឱ្យមានយុវជនមួយចំនួនឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ក្នុងចំណោមយុវជននេះ យើងមានលោកឪពុក ឆ្មារ សាឡាស លោកឪពុក សាឡឹម និងលោកឪពុក សំរើន ដែលនៅមុខយើង ទាំងបីនាក់បានស្លាប់នៅក្នុងសម័យខ្មែរក្រហម និងទាំងបីនាក់ចូលនៅក្នុងបញ្ជីរឈ្មោះដែលព្រះសហគមន៍កំពុងពិចារណាធ្វើជាមរណសាក្សីផ្លូវការ។

នៅឆ្នាំ១៩៧០ ពេលចាប់ផ្តើមសម័យ លុន នល់ សង្គ្រាមស៊ីវិលដែលបើកប្រវត្តិសាស្ត្រដ៏ពិបាកបំផុតនៅប្រទេសកម្ពុជា។ នៅពេលក្រុមខ្មែរក្រហមចាប់ផ្តើមវាយចូលនៅក្នុងព្រៃ នៅពេលគ្រាប់មីនធ្លាប់ពីលើដោយកងទ័ពអាមេរិកទម្លាក់លើប្រទេសកម្ពុជា។ នៅពេលជនជាតិវៀតណាមជាពិសេសជាមួយបងស្រី ជាមួយសាសនទូតមួយចំនួនត្រូវតែចេញពីប្រទេសកម្ពុជា មួយចំនួនទៅប្រទេសវៀតណាម ខ្លះទៅប្រទេសបារាំង។ នៅពេលលោកអភិបាលបានរៀបចំជាមួយលោកឪពុក អេមីល អង្គការការីតាសដើម្បីឱ្យយើងបង្ហាញធម៌មេត្តាករុណានៅក្នុងពេលវេលាដ៏ពិបាកនេះ។ នៅពេលលោកអភិបាលនៅជាមួយក្រុមគ្រួសារព្រះសហគមន៍ខ្មែរដ៏តូចមួយ នៅពេលលោកអភិបាលឃើញវិសាលវិហារត្រូវគេបិទទ្វារ និងផ្ទះលោកអភិបាលនៅផ្លូវមុនីវង្សបាត់បង់សុវត្ថិភាពពីមួយថ្ងៃទៅមួយថ្ងៃ។ ជាពេលវេលាដែលលោកអភិបាល ត្រូវការជ្រើសរើសដែលជាជម្រើសមួយដ៏សំខាន់បំផុសនៅក្នុងជីវិតរបស់លោកអភិបាល គឺ "**តើខ្ញុំនៅប្រទេសកម្ពុជាតទៅទៀត ឬខ្ញុំទៅបារាំងវិញ?**"។ នៅពេលនោះ លោកតាបានជ្រើសរើសនៅលើទឹកដីប្រទេសកម្ពុជានៅជាមួយព្រះសហគមន៍ នៅជាគ្រូគង្វាលដ៏សប្បុរសរបស់បងប្អូនទាំងអស់។ ការជ្រើសរើសនេះ

បានណែនាំឱ្យលោកអភិបាលហៅលោកឪពុក ឆ្មារ សាឡាស ដែលកំពុងសិក្សានៅប្រទេសបារាំងឱ្យត្រលប់មកវិញ ដើម្បីទទួលតែងតាំងជាអភិបាលយ៉ាងស្ងៀមស្ងាត់បំផុត នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ ពេលលោកអភិបាល អ៊ីវ ចេញធ្វើដំណើរទៅប្រទេសថៃ ជាពេលវេលាពិបាកណាស់ ពិបាកតាមផ្លូវវិញ្ញាណ ឈឺចាប់ខាងផ្លូវចិត្ត តាមផ្លូវជាមនុស្សដោយមើលឃើញប្រជារាស្ត្រដ៏ជាទីស្រឡាញ់ត្រូវការចេញទៅតាមផ្លូវ ដែលមានដីហុយទូទាំងប្រទេស ដែលមើលឃើញគ្រប់សកម្មភាពនៃព្រះសហគមន៍ សកម្មភាពវិស័យការសិក្សា ធម៌មេត្តាករុណាត្រូវការបំផ្លាញ ដោយមើលឃើញគ្រប់វិហារ ទាំងវិសាលវិហារត្រូវគេវៃចោល។ ខ្ញុំជឿថា នៅពេលលោកអភិបាលបានធ្វើដំណើរ ពីស្ថានទូតបារាំងទៅដល់ព្រំដែនប្រទេសថៃ នៅពេលខ្មែរក្រហមបានបណ្តេញជនបរទេសទាំងអស់ ជាការឈឺចាប់ដែលយើងមិនអាចគិត មិនអាចយល់។ ការឈឺចាប់ហួសហេតុ សម្រាប់គ្រូគង្វាលដ៏សប្បុរសតាមព្រះហឫទ័យព្រះជាម្ចាស់ និងប្រហែលដូចលោកអប្រាហាំ ដែលថ្ងៃនេះបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ "**ចូរយកអ៊ីសាក់កូនអ្នក គឺកូនប្រុសតែមួយដ៏ជាទីស្រឡាញ់របស់អ្នក ចូរយកវាធ្វើយញ្ញបូជានៅលើភ្នំដែលយើងបង្ហាញប្រាប់អ្នក**" នៅពេលនោះប្រហែលមានអារម្មណ៍ដូចគ្នា។ បុត្រាបុត្រីដែលលោកអភិបាលបានស្រឡាញ់បំផុត ដែលនៅពេលនោះបំពាក់អាវខ្មៅប៉ុន្តែដួងចិត្តនៅសល់ពន្លឺដ៏តូចមួយ គឺពន្លឺនៃជំនឿដែលណែនាំឱ្យគេបានទុកថែរក្សាសេចក្តីសង្ឃឹមតទៅទៀត។ នេះជាព្រះសហគមន៍ ដែលលោកអភិបាលត្រូវការចាកចេញ មិនមែនដោយសារលោកតាបានជ្រើសរើស បានសម្រេចចិត្ត ប៉ុន្តែដោយសារគេបង្ខំ។ លោកបានទៅប្រទេសឥណ្ឌូណេស៊ី និងទទួលខុសត្រូវជនជាតិខ្មែរទូទាំងពិភពលោក បានណែនាំឱ្យលោកអភិបាលត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៨៩។ នៅពេលនោះ អត់មានមូក អត់មានដំបង ប៉ុន្តែមានទ្វារដ៏តូចមួយដែលកំពុងបើក។

ពិតមែនលោកអភិបាល បានថែរក្សាការពារសេចក្តីសង្ឃឹមជានិច្ច យើងដឹងថាព្រះជាម្ចាស់ប្រទានអ្វីៗទាំងអស់ដល់អ្នកបម្រើរបស់ព្រះអង្គ ដូចព្រះជាម្ចាស់បានប្រទានជីវិតដល់លោក អប្រាហាំ ព្រះជាម្ចាស់បានថែរក្សានិងប្រទានជីវិតដល់លោកតាដែរ។ ខ្ញុំជឿថា លោកតាបានរំភើបណាស់នៅឆ្នាំ១៩៨៩ ដែលបានដើរនៅលើផ្លូវមុនីវង្សហើយគ្រីស្តបរិស័ទឃើញ និងបានជួបជុំគ្នានៅភោជនីដ្ឋានមួយ បីដូចជាបង្កើតព្រះសហគមន៍មួយសាជាថ្មី។ នៅពេលនេះ ជាមួយគ្រីស្តបរិស័ទដែលបានគោរពចិញ្ចៀនរបស់លោកអភិបាល ចិញ្ចៀនដែលជាសញ្ញាសម្គាល់នៃភក្តីភាពរបស់លោកតា ភក្តីភាពរបស់គ្រីស្តបរិស័ទ និងជាពិសេសព្រះហឫទ័យដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ចំពោះយើង។ យើងអាចតែកោតសរសើរសេចក្តីក្លាហានរបស់លោកតា ដើម្បីត្រឡប់មកវិញ ដើម្បីចាប់ផ្តើមពីសូន្យទៅ ដើម្បីសាងសង់សាជាថ្មី។ នៅពេលលោកអភិបាលត្រឡប់មកវិញក្លាយជាលោកអភិបាលសាជាថ្មីនៅឆ្នាំ១៩៩២ សម្រាប់ភ្នំពេញ និងទទួលខុសត្រូវសម្រាប់បាត់ដំបង។ នៅពេលនោះ បានយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត ដើម្បីសាងសង់ជំនឿ សាងសង់ចិត្តគំនិតសាជាថ្មី ដើម្បីទិញដី ដើម្បីសម្រុះសម្រួលទំនាក់ទំនងរវាងសន្តអាសនៈនិងប្រទេសកម្ពុជា។ ណែនាំឱ្យព្រះសហគមន៍ប្រទេសកម្ពុជារបស់យើង មានលក្ខន្តិកៈយ៉ាងច្បាស់លាស់

ដើម្បីទទួលស្វាគមន៍ក្រុមសាសនទូតថ្មី ដូចជាក្រុមសាសនទូតថៃ ភីមេ យ៉ារ៉ូម៉ាល់ ដេស្វីត ដុនបូស្កូ បងស្រីដុនបូស្កូ បងស្រីមេត្តាករុណា បុត្រីមេត្តាករុណា បងស្រីដូមីនីកាន់... ដើម្បីទទួលស្វាគមន៍ក្រុមចាស់ ដូចជាក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស បងស្រីឧបការគុណ គ្រួសារពន្លឺមិត្តភាព...។

ខ្ញុំនឹកឃើញលោកតាបានបើកឡាន ជីព ពណ៌ស លោកតាគាត់ឈឺណាស់ ឈឺដៃ ឈឺជើង ... មិនអាចដេកនៅលើគ្រែបានទេ លោកតាដេកនៅលើកៅអីរហូត។ ប៉ុន្តែ លោកនៅតែញញឹមនិងធ្វើដំណើរទូទាំងប្រទេសកម្ពុជា ទោះបីសម័យនោះផ្លូវខូចខ្លាំង ឬអត់មានផ្លូវតែម្តង ប៉ុន្តែលោកបានធ្វើដំណើរពីភ្នំពេញទៅដល់បាត់ដំបង ពីចំណោមទៅស៊ីសុផុន (ដែលលោកតាបានជួបខ្ញុំនៅដើមខែធ្នូ ឆ្នាំ១៩៩៩) ពីប៉ោយប៉ែតទៅសៀមរាប ពីកំពង់ធំទៅក្រុងសីហនុ។ ពិតមែនលោកតាជាគ្រូគង្វាលដ៏សប្បុរស គ្រូគង្វាលដ៏សុភាពរាបសារ នៅក្នុងចំណោមប្រជារាស្ត្ររបស់លោកតា។ លោកតាជាគ្រូគង្វាលដែលយកចិត្តទុកដាក់ណាស់ យកចិត្តទុកដាក់មែនទែន ដើម្បីរៀបចំពិធីបុណ្យ រៀបចំធម្មទេសនា រៀបចំសារលិខិត... លោកតាបានសរសេរដោយអក្សរដ៏តូចរបស់គាត់ ប៉ុន្តែដែលជាសញ្ញាសម្គាល់នៃអ្នកបម្រើដែលយកចិត្តដាក់ និងបម្រើអស់ពីសមត្ថភាព អស់ពីដួងចិត្ត។

លោកតាជាគ្រូគង្វាល ដែលស្វាគមន៍ ដែលស្រឡាញ់ជានិច្ច យើងបានសប្បាយចិត្តនៅពេលគាត់ទៅដល់ក្រុងព្រះសីហនុនៅឆ្នាំ២០០១ ដើម្បីមានសំណាក់ធម៌ មានប្រជុំ គាត់បានស្វាគមន៍យើងជានិច្ច និងយកចិត្តទុកដាក់ជាមួយយើងជានិច្ច ដូចព្រះនាងម៉ារីនៅមង្គលការកាណា។ ពិតមែនលោកតាជាគ្រូគង្វាលដែលមានទស្សនៈ ដែលនឹកឃើញអនាគត និងដែលបានរៀបចំទាំងនៅឆ្នាំ១៩៧៥ ទាំងនៅឆ្នាំ១៩៩៧ និងឆ្នាំ២០០០។ លោកតាបានរៀបចំព្រះសហគមន៍កាតូលិកនៅកម្ពុជា ដើម្បីឱ្យយើងមានគ្រូគង្វាលតទៅទៀត ដើម្បីយើងមានគ្រប់អ្វីៗទាំងអស់ ឱ្យយើងបម្រើប្រជារាស្ត្ររបស់ព្រះអង្គអស់ពីដួងចិត្ត។ សន្តប៉ូល នៅថ្ងៃនេះបានសរសេរថា "**ព្រះជាម្ចាស់ណែនាំមនុស្សដែលព្រះអង្គបានជ្រើសរើស ទៅជាមនុស្សសុចរិត**"។ លោកអភិបាល អ៊ីវ ព្រះជាម្ចាស់បានណែនាំឱ្យលោកអភិបាល ទៅជាមនុស្សសុចរិតពិតមែន យើងជាសាក្សីបន្ទាល់នៅពេលនេះ។ សូមលោកអភិបាលអធិដ្ឋានសម្រាប់យើង អធិដ្ឋានសម្រាប់ខ្ញុំ អធិដ្ឋានពីស្ថានបរមសុខសម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជា ដើម្បីឲ្យយើងទាំងអស់គ្នា យើងអាចបម្រើ និងស្រឡាញ់ព្រះសហគមន៍យើង កសាងព្រះរាជ្យរបស់ព្រះជាម្ចាស់លើទឹកដីកម្ពុជាយើង។ មេត្តាករុណា មុទិតា និងឧបេក្ខា ចូលនៅក្នុងភាពញញឹមរបស់លោកតា។ សូមបន្តញញឹម សូមបន្តសើចដោយមើលយើងពីស្ថានបរមសុខ ដើម្បីយើងទាំងអស់គ្នាយើងកែប្រែចិត្តគំនិត ជាពិសេសនៅ

ក្នុងរដូវសែសិបថ្ងៃនេះ ដើម្បីឱ្យដួងចិត្តរបស់យើងភ្ជាប់នឹងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។

លោកអភិបាល អ៊ីវ សូមគង់នៅស្ថានបរមសុខ នៅក្នុងសេចក្ដីសុខ និងសូមជម្រាបសួរបងប្អូនរបស់យើងនៅក្នុងជំនឿ លោក ឆ្មារ សាឡាស និងសហការី និងបងប្អូនទាំងអស់ដែលនៅស្ថានលើហើយ។ ពេលយើងញាំបាយថ្ងៃត្រង់យូរនៅផ្ទះលោកអភិបាល ពេលលោកអភិបាល អ៊ីវ គិតថាល្មមហើយគាត់និយាយជាភាសាបារាំងថា «បុង» ជាភាសាខ្មែរ «បាទ»។ ពេលយើងលឺពាក្យបាទរបស់គាត់ យើងដឹងថាល្មមក្រោកចេញពីតុបាយដើម្បីបន្តការងាររបស់យើង។ ដូច្នេះ ខ្ញុំគិតថា នៅក្នុងភាពងងឹតនៅមន្ទីរពេទ្យថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១នេះ ព្រះជាម្ចាស់មានព្រះបន្ទូលមួយដល់លោកតា ហើយលោកតាបានឆ្លើយថា «បាទ» ឬ «បុង»។ លោកតាបានឆ្លើយតបទៅព្រះជាម្ចាស់អស់មួយជីវិត នៅក្នុងដង្ហើមចុងក្រោយលោកបានឆ្លើយថា «**ខ្ញុំទេតើ! ជាអ្នកបម្រើរបស់ព្រះអង្គ**»។ អាម៉ែន៕